# គំរោង : ជួយសហគមន៍យើង

ផ្តល់ថវិកាដល់គំរោងខ្នាតតូចដែលដឹកនាំដោយយុវជន

## <u>ពាក្យស្នើរសុំ</u>

## ឈ្មោះទីកន្លែងគំរោង

| ១.អត្តសញ្ញាណនៃគំរោង | |
|---|---|
| ១.១ ឈ្មោះគំរោង ៖ សូមដាក់ឈ្មោះដែលងាយចាំ ដែលសង្ខេបនូវគោលបំណងរបស់អ្នក ( ត្រឹម ២០ពាក្យ) | |
| បង្កើតមុខរបរ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់យុវជននៅតាមជនបទ | |
| ១.២ វិស័យសំខាន់នៃគំរោង | |
| គំរោងយើង នឹងធ្វើការអនុវត្តទៅលើវិស័យ | |
| ☑ អប់រំ បណ្តុះបណ្តាល ឬជំនាញវិជ្ជាជីវៈ | ☐ សិទ្ធមនុស្ស និង បញ្ហាយែនឌ័រ |
| ☐ គំរោងទាកទ់ងនឹងបញ្ហាសុខភាព | ☐ សំភារៈ វិស្ថាប័ន សំរាប់យុវជន |
| ☑ គំរោងបង្កើតប្រាក់ចំនូល | ☐ ធនធានទឹក |
| ☐ ពតិមានវិទ្យា សិល្បៈ និងការប្រាស្រ័យទាក់ទង | ☐ ផ្សេងៗ -( សូមបញ្ជាក់) |
| ☐ ការអភិរក្សបរិស្ថាន | - |
| ☐ កសិកម្ម | - |

---

| ២.ក្រុមការងាររបស់គំរោង |
|---|
| *២.១ ពតិមានអំពីអ្នកគ្រប់គ្រងវ័យក្មេង* |

| | |
|---|---|
| នាមត្រកូល និងនាមខ្លួន : កែវ ប៉េស្សេ | ថ្ងៃខែឆ្នាំកំនើត : ១២/០២/១៩៨៥ **(DD/MM/YYYY)** |

អ៊ីម៉ែល: huot_tkh@yahoo.com

លេខទូរស័ព : ៨៥៥-៨៩ ២៨៧ ០១៦

*(សូមសរសេរជាលេខកូដអន្តរជាតិ)*

អាស័យដ្ឋាន : រស់នៅ ភូមិពោធិ៍កណ្តាល ឃុំពោធិ៍អង្រ្កង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា

ក្រុមយើងខ្ញុំបានទទួលពតិមានអំពីគំរោង ***ជួយសហគមន៍យើង*** នេះតាមរយៈបុគ្គលិករបស់អង្គការសេដាក

២.២ ពតិមានអំពីសមាជិកក្រុមគំរោងយុវជនវ័យក្មេង

| នាមត្រកូល និងនាមខ្លួន | អាយុ | តួនាទីក្នុងគំរោង |
|---|---|---|
| កែវ ប៉េស្សេ | ២៤ ឆ្នាំ | អ្នកគ្រប់គ្រងគំរោង |
| ចក់ សរិត | ២៤ ឆ្នាំ | គ្រូបង្គោល |
| ពេញ ស៊ីថា | ២៣ ឆ្នាំ | គ្រូបង្គោល |
| យួន សោភា | ២៤ ឆ្នាំ | គ្រូបង្គោល |
| ទន គឹមលៀង | ២៤ ឆ្នាំ | គ្រូបង្គោល |

| | |
|---|---|
| ចំនួនអ្នកស្ម័គ្រចិត្ត : ៥ នាក់ | អាយុជាមធ្យម : ២៣ ឆ្នាំ |
| ចំនួនភេទស្រី : ២ នាក់ | ចំនួនប្រុស : ៣ នាក់ |

២.៣ *អ្នកផ្តល់ប្រឹក្សាលើគំរោង* :

ឈ្មោះ : សូ ផាផល

អ៊ីម៉ែល : sopha_phal@online.com.kh

ទូរស័ព្ទលេខ : ៨៥៥-១២ ៦០០ ០៣៨

*(សូមសរសេរជាលេខកូដអន្តរជាតិ)*

អាស័យដ្ឋាន : ផ្ទះសង់ថ្មី ភូមិភ្នំពេញថ្មី ផ្លូវ ១០០៣ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

មុខរបរ ឬបទពិសោធន៍ : ជាបុគ្គលិករបស់អង្គការសេដាក តួនាទីជាអ្នកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលយុវជន

| |
|---|
| ២.៤ អ្នកវាយតំលៃគំរោង : |
| ឈ្មោះ : ទន គីមហួត |
| អ៊ីម៉ែល : tornkimhuot@yahoo.com |
| ទូរស័ព្ទលេខ : ៨៥៥-៨៩ ៩៩១ ២០១<br>*(សូមសរសេរជាលេខកូដអន្តរជាតិ)* |
| អាស័យដ្ឋាន : រស់នៅភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ |
| មុខរបរ ឬបទពិសោធន៍ : អ្នកសម្របសម្រួលក្រុមយុវសហគ្រិនប្រចាំខេត្តតាកែវ |

| ៣.អង្គភាព :( ប្រសិនបើអ្នកជាសមាជិក ឬបានទទួលការគាំទ្រពីអង្គការណាមួយ សូមបំពេញខាងក្រោម) | |
|---|---|
| ឈ្មោះ : សេដាក (CEDAC) | ទូរស័ព្ទ : ៨៥៥-២៣ ៨៨០ ៩១៦ |
| គេហទំព័រ : www.cedac.org.kh | ទូរសារ : ៨៥៥-២៣ ៨៨០ ១៤៦ |
| អ៊ីម៉ែល : cedac@online.com.kh | អាស័យដ្ឋាន : ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ |

បេសកកម្ម និងសកម្មភាពដែលទាក់ទងនឹង គំរោងនេះដូចជា:

- ផ្តល់ឱកាសដល់យុវជននៅតាមជនបទដែលមិនមានលទ្ធភាពរៀនបន្ត និងគ្មានការងារធ្វើ ឱ្យបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងកាងារអភិវឌ្ឍន៍ ដល់យុវជនឱ្យចេះបង្កើតការងារដោយខ្លួនឯង និង មានអាជីពច្បាស់លាស់
- មានសកម្មភាពបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម ឬគំនិតថ្មីទៅដល់កសិករ និងយុវជននៅតាមជនបទ
- មានបង្កើតក្រុមយុវជន ឬបណ្តាញយុវជន និងក្រុមសន្សំប្រាក់នៅតាមជនបទ

៤. ទីកន្លែងអនុវត្តគំរោង : **នៅជនបទ** /ទីប្រជុំជន *(សូមគូសរង្វង់ជ្រើសរើសយកចំលើយមួយ)*

៤.១ ស្ថានភាពនៃគំរោង : *សូមពន្យល់ត្រួស១ពីទីកន្លែងអនុវត្តគំរោង- សហគមន៍របស់អ្នកនិងស្ថានភាពរបស់អ្នក (ច្រើនបំផុត ២៥០ពាក្យ)៖*

តំបន់គោលដៅរបស់គំរោង បង្កើតមុខរបរ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់យុវជននៅតាមជនបទ គឺមានចំនួន ៤ភូមិ ដែលស្ថិតនៅក្នុង ៤ឃុំ ៣ស្រុក ២ខេត្តដែលជាប់គ្នា គឺខេត្ត តាកែវ និងកំពង់ស្ពឺ។ ហើយស្ថានភាពនៃគំរោងនៃ

តំបន់គោលដៅគឺមានដូចជាៈ

– វិស័យកសិកម្មគឺ ពុំទាន់មានការលូតលាស់ល្អជឿនលឿនទេ គឺនៅតែធ្វើការចិញ្ចឹម និងដាំដំណាំតាមទំលាប់ ឬតាមយថាផល
– យុវជននៅតំបន់គោលដៅរៀនសូត្របានតិចតួច ភាគច្រើនឈប់រៀន ឬបញ្ចប់ការសិក្សាត្រឹមអនុវិទ្យាល័យ
– ពុំទាន់មានកន្លែងសំរាប់ផលិតពូជដំណាំ និងផ្គត់ផ្គង់ពូជដំណាំនោះទេ
– ប្រជាជននៅតំបន់នោះគឺរកចំណូលពីការងារកសិកម្មបានតិចតួចដោយសារពួកគាត់មិនយកចិត្តទុកដាក់អំពីការងារកសិកម្ម
– យុវជនមិនមានការចាប់អារម្មណ៍ទៅលើការងារកសិកម្មដែលនាំឱ្យពួកគេពុំមានការងារធ្វើ និងចំណាកស្រុកច្រើន
– យុវជនគ្មានការងារធ្វើនៅតាមជនបទដើរលេងឥតប្រយោជន៍នាំឱ្យមានការបង្កើតក្រុមបងតូចបងធំ នាំឱ្យមានអំពើអសន្តិសុខដល់សង្គម

៤.២ តំរូវការជាក់លាក់ និងចាំបាច់: *សូមពិពណ៌នាលើតំរូវការចាំបាច់របស់សហគមន៍ដែលគំរោងរបស់អ្នកផ្តោតទៅលើ។ តើកម្មវត្ថុរបស់អ្នកគឺជាអ្វី?(ច្រើនបំផុត១០០ ពាក្យដោយមាន៥ចំនុចធំៗ)*

នៅក្នុងតំបន់គោលដៅមានតំរូវការជាក់លាក់ និងចាំបាច់ដូចជាៈ

– ការបណ្តុះបណ្តាលអំពីចំណេះដឹងជំនាញ បច្ចេកទេសកសិកម្មដល់យុវជន
– ធ្វើឱ្យយុវជនមានមុខរបរពិតប្រាកដ និងមានប្រាក់ចំណូលសំរាប់គ្រួសាររបស់ពួកគេ ដើម្បីកុំឱ្យពួកគេមានការចំណាកស្រុក និងចង់ឱ្យពួកគេមានជីវភាពធូធារ
– បង្កើតឱ្យមានគ្រូបង្គោលដែលជាគ្រូបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅតាមភូមិនិមួយៗ សំរាប់ជាគំរូ និងសំរាប់បណ្តុះបណ្តាលណែនាំដល់យុវជនជំនាន់ក្រោយទៀត
– បង្កើតក្រុមយុវជននៅតាមភូមិគោលដៅ ដើម្បីឱ្យយុវជនមានការសហការគ្នាចេះចែករំលែក និងជួយគ្នាទៅវិញទៅមក
– បង្កើតឱ្យមានកសិដ្ឋានសំរាប់ធ្វើការផ្គត់ផ្គង់ពូជដំណាំ និងកន្លែងសំរាប់រៀនសូត្រនៅក្នុងភូមិ

៥. សង្ខេបគំរោង : *សូមពន្យល់ជាទូទៅនូវរាល់សកម្មភាពដែលគំរោងអ្នកនឹងអនុវត្តន៍(ច្រើនបំផុត ២៥០ពាក្យ)*

គំរោង បង្កើតមុខរបរ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់យុវជននៅតាមជនបទ ដែលបានបង្កើត និង រៀបចំដោយក្រុមយុវជនចំនួន ៥នាក់ដែលជាសិស្សសហគ្រិនរបស់អង្គការសេដាក ហើយគំរោងនេះគឺធ្វើការអនុវត្តន៍ទៅលើ វិស័យ

បង្កើតប្រាក់ចំណូល និងអប់រំបណ្តុះបណ្តាល ឬជំនាញវិជ្ជាជីវៈ ។ ដោយសារតែនៅក្នុងតំបន់គោលដៅជួបបញ្ហាដូចជា : យុវជនខ្វះចំណេះដឹងជំនាញ បច្ចេកទេសកសិកម្ម ,យុវជនមិនមានមុខរបរពិតប្រាកដ និងគ្មានប្រាក់ចំណូលសំរាប់គ្រួសារ នាំឱ្យពួកគេមានការចំណាកស្រុក ,ខ្វះគ្រូបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅតាមភូមិគោលដៅ សំរាប់ជាអ្នកគំរូ និងគ្រូសំរាប់ បណ្តុះបណ្តាលណែនាំដល់យុវជនជំនាន់ក្រោយទៀត ,យុវជនមិនមានការសហការគ្នាគ្មានការចែករំលែក និងជួយគ្នាទៅវិញទៅមក ដែលនាំឱ្យមាន កើតក្រុមបងតូច បងធំនៅក្នុងភូមិ ។

ហេតុដូចនេះហើយទើបយើងធ្វើការរៀបចំគំរោងសំរាប់ដោះស្រាយ និងបំពេញតំរូវការទាំងនោះដោយធ្វើការអនុវត្តន៍នូវសកម្មភាពដើម្បីដោះស្រាយដូចជាៈ សកម្មភាពរៀបចំកសិដ្ឋាន និងកន្លែងសំរាប់សិស្សសិក្សារៀនសូត្រ ចំនួន ៥ កសិដ្ឋានៈ ហើយកសិដ្ឋានគឺមានសារៈសំខាន់ សំរាប់ជាកន្លែងរៀនសូត្ររបស់សិស្ស និងការពិសោធន៍ផ្ទាល់ ជាពិសេសកន្លែងសំរាប់ផ្គត់ផ្គង់ដំណាំពូជក្នុងភូមិ, រៀបចំក្រុមយុវជននៅតាមភូមិគោលដៅឱ្យបានចំនួន ១ក្រុម/ភូមិៈ ដើម្បីងាយស្រួលក្នុងការបណ្តុះបណ្តាលដល់យុវជន នៅតាមភូមិ គោលដៅ និងបង្កើតប្រាក់សន្សំនៅក្នុងក្រុម ,រៀបចំការបណ្តុះបណ្តាល ដល់យុវជននៅតាមភូមិគោលដៅអំពី បច្ចេកទេស កសិកម្ម មានបច្ចេកទេសចិញ្ចឹមមាន់ ,ចិញ្ចឹមជ្រូក និងការដាំដំណាំដល់យុវជននៅក្នុងភូមិគោលដៅ ,រៀបចំការទស្សនៈ កិច្ចសិក្សារៀនសូត្រទៅមើលកសិដ្ឋានកសិករឆ្នើមដែលអនុវត្តន៍បានល្អដែលអាចរៀនសូត្របាន ដើម្បីមើលពី ការអនុវត្តន៍ ជាក់ស្តែងរបស់កសិករដែលអនុវត្តន៍បានល្អ និងចុះជួយជំរុញ និងផ្តល់យោបល់ណែនាំដល់សិស្សនៅតាមភូមិ គោលដៅ ។

| ៦.កាលវិភាគគំរោង-លំដាប់លំដោយពេលនៃគំរោង( អាចសរសេរបានតាមតំរូវការ) | |
|---|---|
| បង្កើតពេលលំអិតនៃគំរោងគិតជាថ្ងៃ សប្តាហ៍ តាមរយៈពេលគំរោង : ៦ ខែ( ០១/០៩/២០០៩ -២៩/០២/២០១០) | |
| កាលចាប់ផ្តើម | សកម្មភាព |
| | |
| សប្តាហ៍ទី ១ ដល់ សប្តាហ៍ទី ៤ | ធ្វើការរៀបចំកសិដ្ឋាន និងកន្លែងរៀនសូត្រសំរាប់យុវជន នៅតាមភូមិគោលដៅនិមួយៗ ចំនួន ៤ កសិដ្ឋាន |
| សប្តាហ៍ទី ៥ | ធ្វើការរៀបចំវិធីសាស្រ្ត និងប្រធានបទសំរាបបណ្តុះបណ្តាលដល់យុវជននៅតាមភូមិគោលដៅ |
| សប្តាហ៍ទី ៦ ដល់ ទី៧ | រៀបចំក្រុមយុវជនដែលត្រូវបណ្តុះបណ្តាលនៅតាមភូមិគោលដៅ |
| សប្តាហ៍ទី ៨ ដល់ ទី ១២ | រៀបចំការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់យុវជននៅតាមភូមិគោលដៅ , រៀបចំកម្មវិធីទស្សនៈកិច្ចសិក្សាទៅរៀនពីកសិករដែលឆ្នើមៗ របស់អង្គការសេដាក និង |

| | |
|---|---|
| | ចុះផ្តល់យោបល់ដល់យុវជននៅតាមភូមិ និមួយៗ |
| សប្តាហ៍ទី ១៣ | ធ្វើការវាយតំលៃគំរោង រយះពេល ៣ខែ |
| សប្តាហ៍ ទី ១៤ ដល់ទី ២២ | ធ្វើការចុះផ្តល់យោបល់ណែនាំ, តាមដាន ,ជួយជំរុញដល់យុវជនដែលបានទទួលការបណ្តុះបណ្តាលរួច និង ជាពិសេសគឺ យើងធ្វើការរៀបចំការបណ្តុះបណ្តាលរំលឹកពីបច្ចេកទេសដែលបានរៀនកន្លងមក |
| សប្តាហ៍ទី ២៣ ដល់ ទី២៤ | ធ្វើការវាយតំលៃបញ្ចប់គំរោងរយះពេល ៦ខែ |

| |
|---|
| ៧. អ្នកទទួលផល : -សូមពន្យល់អំពីអ្នកទទួលផលប្រយោជន៍ពីគំរោង — *ចំនួនអ្នកទទួលផលប្រយោជន៍ អាយុ ភេទ ប្រវត្តិរូបសង្ខេបរបស់ពួកគាត់ និងថាតើពួកគាត់នឹងជាប់ពាក់ព័ន្ធក្នុងគំរោងដោយរបៀបណា ។( ច្រើនបំផុត ២00ពាក្យ)* |
| ចំពោះអ្នកដែលទទួលផលប្រយោជន៍របស់គំរោងវិញគឺមាន:<br>- ក្រុមទី ១ គឺ : ក្រុមអ្នកដែលប្រតិបត្តិគំរោង ចំនួន ៥នាក់ ស្រី ២នាក់ ប្រុស៣ នាក់  ដែលពួកគាត់ជាអ្នកអនុវត្តន៍គំរោងផ្ទាល់ ហើយនឹងជាគ្រូបណ្តុះបណ្តាលដល់យុវជន ជាពិសេសពួកគេគឺត្រូវតែរៀបចំកសិដ្ឋានក្នុង ១នាក់ ១កសិដ្ឋាន<br>- ក្រុមទី ២ គឺ : ក្រុមយុវជននៅតាមភូមិ ចំនួន ៤ក្រុមស្មើនឹង ៤0 នាក់ ប្រុសចំនួន ១៥ នាក់ និង ស្រីចំនួន ២៥នាក់ ហើយអាយុ ជាមធ្យមគឺ ២៣ ឆ្នាំ ។ ហើយផលប្រយោជន៍ដែលពួកគេទទួលបានគឺចំណេះដឹងបច្ចេកទេសកសិកម្ម និង ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំនើរ និងថ្លៃអាហារនៅពេលចូលរួមការបណ្តុះបណ្តាល ,ទស្សនះកិច្ចសិក្សា ... ។ល ។<br>- ក្រុមទី ៣ គឺ: ជាអ្នកទទួលផលប្រយោជន៍ប្រយោល គឺកត្តាជះឥទ្ធិពលដល់យុវជនដទៃទៀតដែលនៅក្នុងភូមិ និង ក្រៅភូមិ ចំនួន ៦0 នាក់ ។ ហើយផលប្រយោជន៍ដែលពួកគេទទួលបានគឺចំណេះដឹងបច្ចេកទេសកសិកម ។ |
| ៨. លទ្ធផល/កត្តាចង្អុលបង្ហាញ : *សូមពន្យល់វត្ថុសៗនូវភាពខុសគ្នាដែលគំរោងរបស់អ្នកនឹងផ្តល់ ព្រមទាំងលើកឡើងអោយបាន ៤ចំណុចអំពីលទ្ធផលដែលនឹងសំរេចបាន និងកត្តាចង្អុលបង្ហាញនិមួយៗ ។* |

| លទ្ធផល | កត្តាចង្អុលបង្ហាញ |
|---|---|
| ១ មានកសិដ្ឋានសំរាប់ជាកន្លែងរៀនសូត្រ | ១ មានកសិដ្ឋាន ចំនួន ៥កសិដ្ឋាន |
| ២ អោយក្មេងៗអនុវត្តន៍ការងារកសិកម្ម និង មានប្រាក់ចំណូល | ២ ការចិញ្ចឹមមាន់ និងដាំដំណាំ ចំនួន ៤0នាក់ និង ចំណូលក្នុងម្នាក់ ១0ម៉ឺនរៀលក្នុង ១ខែ |

| | |
|---|---|
| ៣ មានក្រុមយុវជននៅតាមភូមិគោលដៅ | ៣ ចំនួន ៤ក្រុម |
| ៤ យុវជនមានការសន្សំប្រាក់នៅក្នុងភូមិគោលដៅ | ៤ ចំនួន ៤ក្រុម |
| ៥ កាត់បន្ថយការចំណាកស្រុករបស់យុវជន ក្នុងភូមិគោលដៅ | ៥ កាត់បន្ថយការចំណាកស្រុក ចំនួន ៤0នាក់ ក្នុង ៤ភូមិ |

| ៩.ប្រភពធនធាន | | | |
|---|---|---|---|
| ៩.១ ថវិកា | | | |
| ឈ្មោះរូបិយប័ណ្ណក្នុងស្រុក : រៀល (រ) | | | |
| មុខចំនាយត្រូវការ | បរិមាណ | តំលៃឯកតា (តាមរូបបិយប័ណ្ណខាងលើ) | ចំនាយសរុប (តាមរូបិយប័ណ្ណខាងលើ) |
| វិនិយោគទុនធ្វើកសិដ្ឋាន | ៥ នាក់ | ៤១0000 | ២ 0៥0 000 រៀល |
| បណ្តុះបណ្តាល | ៣២ ថ្ងៃ | ៣0 000 | ៩៦0 000 រៀល |
| សំភារៈសំរាប់បណ្តុះបណ្តាល | ១ ដង | ២៤៦ 000 | ២៤៦ 000 រៀល |
| វាយតំលៃគំរោង | ២ ដង | ៨២ 000 | ១៦៤ 000 រៀល |
| រៀបចំទស្សនៈកិច្ចសិក្សា | ៤ ដង | ១៥៣ ៣00 | ៦១៣ ២00 រៀល |
| | | | |
| សរុប (តាមរូបិយប័ណ្ណក្នុងស្រុក) | | | ៤ 0៣៣ ២00 រៀល |
| | | | |
| អត្រាប្តូរប្រាក់ : US-$ 1 = 4100 រៀល | | | |
| សរុប(ជា**US-$**) | | | ៩៨៣.៧0 $ |
| ចំនួនស្នើពី **HOC** (ជា US-$) | | | ៩៨៣.៧0 $ |
| សហដៃគូជំនួយ (ជា US-$),បើមាន | | | 0 |

| ឈ្មោះប្រភពជំនួយ<br>៩.២. សហដៃគូជំនួយ | ចំនួនជា US-$ | មានគំរោងនឹងសុំ(E) | កាលបរិច្ឆេទ (DD/MM/YYYY) |
|---|---|---|---|
| គ្មាន | 0 | 0 | 0 |
| ជំនួយវិភាគទាន | | | |
| (គ្មាន) | | | |

| ៩.៣ ជំនួយវិភាគទាន |
|---|
| ប្រភពវិភាគទានភាគ ច្រើនអាចរកបានដោយមិនចាំបាច់ចំណាយប្រាក់!<br>❖ មានការជួយផ្តល់យោបល់ពីបុគ្គលិករបស់អង្គការសេដាក<br>❖ គ្រូបង្គោលរបស់គំរោងបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មពីអង្គការសេដាក<br>❖ មានការិយាល័យរបស់អង្គការសេដាកសំរាប់ធ្វើការអនុវត្តគំរោង |

៩.៤ គំរោងបង្កើនប្រាក់ចំណូលៈ មានយុវជនជាច្រើនបានអនុវត្តន៏គំរោងបង្កើនប្រាក់ចំណូល ។ ប្រសិនបើអ្នកមិនអាចប៉ាន់ស្មាននូវចំណូលដែលនឹងបានមកពីផលិតផលឬសេវារបស់អ្នកសូមរំលងចំណុចនេះហើយឆ្លើយសំនួរទី ១ ដែលមានជាបន្តបន្ទាប់ ។

| ឯកតានឹងលក់(បើមាន) | តំលៃ (រូបិយប័ណ្ណក្នុងស្រុក) | ចំនួននឹងលក់ ក្នុង ១ឆ្នាំ | ចំនួនលក់បានសរុប ក្នុង ១ឆ្នាំ (រូបិយប័ណ្ណក្នុងស្រុក) | ចំនួនលក់បានសរុប ក្នុង ១ឆ្នាំ (ជាដុល្លា) |
|---|---|---|---|---|
| កូនមាន់ ២០0ក្បាល/ដង | ៣000 រៀល | ៦ | ៣ ៦00 000 រៀល | ៨៧៨ $ |
| លក់មាន់សាច់ ៨0Kg/ដង | ១២000 រៀល | ៤ | ៣ ៨៤0 000 រៀល | ៩៣៦ $ |
| លក់ជ្រូកសាច់ ១៥0Kg/ដង | ១0000 រៀល | ៣ | ៤ ៥00 000 រៀល | ១0៩៧ $ |
| លក់បន្លែ ៥0Kg/ដង | ៤000 រៀល | ៥ | ១ 000 000 រៀល | ២៤៣ $ |
| សរុប : | | | ១២ ៩៤0 000 រៀល | ៣១៥៤ $ |

| |
|---|
| ១ នៅក្នុងតំបន់ជិតខាងភូមិគោលដៅនេះគឺពុំមានក្រុមហ៊ុន ឬអង្គការផ្សេងៗដែលកំពុងអនុវត្តន៍គំរោងបែបនេះទេ។ |
| ២ មានមនុស្សចំនួន ៨0នាក់និងត្រូវការផលិតរបស់យើង ។ ហើយមានទីផ្សារសំរាប់ទទួលផលិតផលនេះគឺ មានទីផ្សារកសិផលធម្មជាតិរបស់អង្គការសេដាកជាអ្នកទទួលទិញ និងមានឈ្មួញដែលទទួលទិញ បន្តសំរាប់លក់ដល់ទីផ្សារក្នុងសង្គម។ |
| ៣ ចំណូលសុទ្ធរបស់ក្រុមយើងមានជាមធ្យម ៣១៥៤ ដុល្លា/ឆ្នាំ ។ |
| ៤ គឺយើងមានតំរូវការលើការចេញច្បាប់អនុញ្ញាតលើការអនុវត្តន៍គំរោងនេះ គឺ បានទទួលការអនុញ្ញាតពីអាជ្ញាធរឃុំ ។ |
| ៥ តំលៃលើទីផ្សានៃផលិតផលឬសេវារបស់យើងមាន<br>- កូនមាន់ ៣000 រៀល/ក្បាល<br>- មាន់សាច់ ១២000 រៀល/Kg<br>- ជ្រូកសាច់ ១0000 រៀល/Kg<br>- បន្លែ ៤000 រៀល/Kg |

| ១0. និរន្តភាពនៃគំរោង : |
|---|
| ក្រោយពេលយើងចប់គំរោង គឺយើងនឹងឱ្យមាន :<br>- អ្នកអនុវត្តន៍មានកន្លែង និងកសិដ្ឋានសំរាប់អោយយុវជនផ្សេងៗទៀត និងរៀនសូត្រ ៥កន្លែង<br>- មានគ្រូបង្គោល ៥នាក់ ជាអ្នកផ្តល់ចំណេះដឹង និងជំរុញបន្ថែមដល់យុវជនក្នុងភូមិគោលដៅ និង យុវជនភូមិផ្សេងៗទៀត<br>- យុវជនអាចរកប្រាក់ចំណូលបានតាមរយៈការអនុវត្តន៍បច្ចេកទេសកសិកម្ម<br>- នៅមានក្រុមយុវជន និងក្រុមសន្សំប្រាក់នៅក្នុងភូមិគោលដៅបន្តអនុវត្តន៍សកម្មភាពបន្តទៀត។ |